# ៧.                    រឿង ប្រាសាទនាងខ្មៅ(១)

បើយើងធ្វើដំណើរពីក្រុងភ្នំពេញ ទៅកាន់ខេត្តតាកែវ ដល់ទៅឃុំរវៀង ស្រុកសំរោង យើងនឹងឃើញវត្ត បុរាណមួយហៅ " វត្តប្រាសាទនាងខ្មៅ " តាំងនៅខាងកើតជាប់នឹងថ្នល់ជាតិពីក្រុងភ្នំពេញទៅ ។

បានជាហៅថា វត្តប្រាសាទនាងខ្មៅ ព្រោះក្នុងវត្តនោះមានប្រាសាទបុរាណពីរ ឈ្មោះប្រាសាទនាងខ្មៅ នៅខាងលិចវិហារចំខ្លោងទ្វារវត្តខាងទិសបស្ចិម ។ ប្រាសាទទាំងពីរនោះ ធ្វើពីថ្មផង ឥដ្ឋផង ទំហំ ៤ ម៉ែត្រ ៤ ជ្រុង កម្ពស់ ១០ ម៉ែត្រ កំពូលស្រួចដូចចេតិយ ខ្ពស់ត្រដែត ។

រឿងព្រេងទាក់ទងដោយដើមកំណើតនៃប្រាសាទនោះ មានដំណាលថា ៖

ក្នុងអតីតកាលកន្លងយូរទៅហើយ មានស្តេចមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទ សុរិយាទេវង្ស គង់នៅ លើភ្នំជីសូរ ជាស្តេចមានមហិទ្ធិឫទ្ធិមានបុណ្យច្រើន ទ្រង់បានសាងប្រាសាទ ៥ និងទ្រង់ឲ្យជីកស្រះ ៤ នៅលើភ្នំនោះ គ្រប់ជ្រុងប្រាសាទ ទ្រង់មានព្រះរាជបុត្រី ១ ព្រះអង្គព្រះនាម នាងខ្មៅ ។

ភ្នំជីសូរអំពីកំពូលចុះមកដល់ដីជម្រាលជើងភ្នំខាងក្រោម ប្រហែល ៧០០ ម៉ែត្រ មានទន្លេ ៤ គឺទន្លេអុំ ១ ទន្លេស្លូត ១ ទន្លេស្តុក ១ ទន្លេប្រទ្រុន ១ ។ ទន្លេទាំង ៤ នោះជាកន្លែងសម្រាប់ក្រសាលរបស់ស្តេចអង្គ នោះ ។ លុះព្រះរាជបុត្រីមានវ័យវឌ្ឍនាការចម្រើនឡើងបានព្រះជន្ម ១៦ ឆ្នាំ ព្រះនាងមានរូបឆោម លោមពណ៌ល្អដាច់ស្រីក្នុងព្រះនគរ ។ ថ្ងៃមួយ ព្រះនាងនឹកត្អូកចង់ទៅលេងទន្លេប្រទ្រុន បានចូលទៅ ថ្វាយបង្គំលាព្រះវរបិតា សុំទៅលេងទន្លេនោះ ។ ព្រះរាជាក៏ទ្រង់ព្រះរាជានុញ្ញាត ហើយទ្រង់ចាត់ មនុស្សបម្រើឲ្យរៀបចំហែហមព្រះដំណើរព្រះនាង ទៅក្រសាលក្នុងវេលាថ្ងៃរសៀល ។

គ្រានោះ មានបុរសម្នាក់ឈ្មោះ បណ្ឌិតស្រី ទើបនឹងសឹកពីសាមណេរ មានរូបឆោមល្អល្អះស្អាតបាត ជាងប្រុសឯទៀត ចេះមន្តអាគមវិជ្ជាការ ។ បណ្ឌិតនោះ ទីលំនៅៗ ភូមិមួយខាងលិចភ្នំជីសូរជិតផ្លូវ ដែលចុះទៅទន្លេប្រទ្រុន ។ ថ្ងៃនេះ បណ្ឌិត ស្រី មានសេចក្តីអផ្សុកចេញទៅលេងជិតផ្លូវនោះ បាន ឃើញព្រះនាងខ្មៅ ចុះពីលើភ្នំ ជាមួយនឹងស្រីបរិវារ ក៏មានសេចក្តីប្រតិព័ទ្ធជាប់ចិត្តនឹងព្រះនាងក្រៃពេក ។ បណ្ឌិតនោះពិចារណាថា "ថ្ងៃនេះជាថ្ងៃមានលាភធំណាស់ដោយបានជួបប្រទះនឹងស្រីគ្រប់លក្ខណ៍ តែអាត្មាអញជាកូនរាស្ត្រអ្នកកម្សត់ ធ្វើម្តេចនឹងបាននាងនោះហ្ន! នាងនេះមិនមែនជាស្រីសាមញ្ញទេ គឺ ជាព្រះរាជបុត្រីរបស់ស្តេច អាត្មាអញនឹងនាងនេះពុំសមស័ក្តិគ្នាសោះ បើដូច្នេះអញត្រូវធ្វើយ៉ាងណាទៅ អែះ?" ។ បណ្ឌិតចេះតែស្រឡាញ់ខ្លាំងឡើងៗ គិតថា "នឹងចូលទៅដណ្តឹងតាមច្បាប់ក៏ពុំសម នឹង ប្រព្រឹត្តខុសក៏មុខជាស្តេចយកទោសដល់ស្លាប់" ។ លុះសេចក្តីស្រឡាញ់កាន់តែទ្វេឡើងៗ ក៏ស៊ូប្តូរ ស្លាប់ថា "ទុកជាស្តេចយកទោសយ៉ាងណា ក៏សុខចិត្តតែស្លាប់" ទើបបាននឹកដល់មន្តវិជ្ជាការ ដែលចេះ

ទាំងប៉ុន្មាន ក៏បេះស្លឹកឈើយកមកសូត្រផ្លុំមន្តវិជ្ជាការនោះ ហើយឡើងដើមឈើផ្លុំស្លឹកបន្លឺឡើង ។ ឯសូរសម្លេងស្លឹកដែលបណ្ឌិតផ្លុំនោះទៅចុចចំបេះដូងព្រះនាងនោះ ព្រះនាងក៏ភ័ន្តភាំងស្មារតី, លុះផ្ងារឡើងគិតថា "អាត្មាអញជាកូនស្តេច ធ្លាប់ស្តាប់ភ្លេងដូរ្យតន្ត្រីសព្វថ្ងៃតែពុំមានភ្លេងអ្វីធ្វើចិត្តឲ្យអញស្លុតដូចសំឡេងស្លឹកនេះសោះ"ព្រះនាងសម្លឹងគិតយូរៗទៅ សំឡេងរឹតតែពីរោះឡើងៗ ព្រះនាងអត់ទ្រាំពុំបាន ក៏លាន់ព្រះឱស្ឋថា "យីអើហ្ន! សំឡេងនេះជាសំឡេងប្លែកណាស់ គួរតែអញទៅតាមស្តាប់មើលឲ្យឃើញច្បាស់ តើអ្នកនោះដូចម្តេចបានជាចេះផ្លុំពីរោះដល់ម្លឹង? " ។ ព្រះនាងក៏ទៅរកមើលឲ្យឃើញដោយព្រះអង្គឯង ។ លុះព្រះនាងទៅជួបឃើញរូបឆោមបណ្ឌិតនោះៗ ក៏រឹតតែមានសេចក្តីប្រតិព័ទ្ធខ្លាំងឡើងបានសាកសួរសន្ទនាគ្នាទៅវិញទៅមក តាមប្រពៃណីរបស់ប្រុសនិងស្រីដែលស្រឡាញ់គ្នា ។ អ្នកទាំងពីររូបបាននិយាយមត់គ្នាថា "ថ្ងៃក្រោយ យើងនឹងមកជួបគ្នាទៀត" ហើយលាបែកគ្នារៀងខ្លួន ។ ចំណែកព្រះនាងចាប់តាំងពីបែកបណ្ឌិតនោះទៅ មានទឹកព្រះភក្ត្រប្លែកពីប្រក្រតី ចេះតែក្រៀមក្រំលែងរួសរាយរកពួកបរិវារពួកបរិវារក៏មានសន្ទិះសង្ស័យ ។ ថ្ងៃក្រោយមក ព្រះនាងចូលលាព្រះរាជាម្តងទៀត ។ ព្រះរាជាក៏ទ្រង់អនុញ្ញាតឲ្យព្រះនាងទៅ ទ្រង់ចាត់មនុស្សឲ្យហែហាមជូនព្រះដំណើរព្រះនាងដូចថ្ងៃមុន លុះទៅដល់កន្លែងនោះ ព្រះនាងនិយាយប្រាប់បរិវារថា " អ្នករាល់គ្នាត្រូវឈប់ចាំខ្ញុំ ខ្ញុំមានកិច្ចឯនោះបន្តិច " ។ និយាយប្រាប់ហើយ ព្រះនាងដើរសំដៅទៅកន្លែងដែលបណ្ឌិតស្រីមកជួប លុះបានជួបគ្នាហើយ ទាំងពីររូបក៏សម្រេចសេចក្តីប្រាថ្នារបស់ខ្លួន ។ ពួកបរិវារសង្ស័យទៅលបមើលឃើញកិរិយាមិនល្អ មានសេចក្តីភិតភ័យ ខ្លាចក្រែងស្តេចយកទោសដល់ជីវិត ក៏ជំនុំពិគ្រោះគ្នាថា "យើងគួរតែក្រាបទូលស្តេចកុំខាន" ។ លុះត្រឡប់ទៅវិញពួកបរិវារក៏ចូលទៅគាល់សព្វគ្រប់តាមដំណើរ ។ ស្តេចទ្រង់ខ្ញាល់ជាខ្លាំងក៏ទ្រង់ហៅពួកពេជ្ឈឃាដមកប្រាប់ថា "ត្រូវយកកូនអញទៅសម្លាប់ឲ្យឆាប់ " ។

ព្រះមហេសីជាព្រះមាតា ក្រាបទូលសុំទោសព្រះស្វាមីថា "សូមព្រះករុណាទ្រង់ព្រះមេត្តាប្រោស ព្រះរាជទានទោសដល់កូនរបស់យើងតែមួយ បើទុកជាមានទោសខុសយ៉ាងណាៗ សូមព្រះអង្គកុំសម្លាប់ គ្រាន់តែបំបរបង់ចេញអំពីទីនេះចុះ សូមទ្រង់អនុញ្ញាតឲ្យទាន" ។ ស្តេចក៏ទ្រង់អនុញ្ញាតតាមសេចក្តីសុំរបស់ព្រះនាងជាព្រះមាតា ទើបទ្រង់បង្គាប់ទៅសេនាបតីឲ្យធ្វើប្រាសាទ ២ ចម្ងាយអំពីព្រះដំណាក់ទៅ ៣ យោជន៍ ។ ពួកសេនាបតីក៏ទទួលធ្វើតាមព្រះរាជបញ្ជា រួចហើយស្តេចទ្រង់បង្គាប់ឲ្យនាំព្រះនាងខ្មៅ ទៅនៅទីនោះ ប្រាសាទនោះនៅខាងលិចភ្នំជីសូរ ។ តាំងពីថ្ងៃនោះទៅ ព្រះនាងកើតទុក្ខជាទម្ងន់ ណាមួយព្រះបិតាបំបរបង់ចោលឲ្យនៅតែម្នាក់ឯង ណាមួយបែកពីរសង្សារ លែងបានមកជួបសោះ ដោយមិនជ្រាបជានៅទីណា ។

គ្រានោះ មានភិក្ខុ ១ រូបឈ្មោះ កែវ លោកនិមន្តចេញពីស្រុកលោក ទៅរៀនមន្តវិជ្ជាការឯស្រុកក្រៅ លោករៀនបានចេះពូកែណាស់ លោកត្រឡប់មកស្រុកវិញគង់នៅទីមួយ (ក្នុងខេត្តតាកែវ) ទីនោះអត់ទឹក អ្នកស្រុកនាំគ្នាជីកស្រះមួយប្រគេនលោក ។ ដោយស្រះនោះជារបស់លោកគ្រូកែវ ទើបមានឈ្មោះថា ស្រះ កែវ ៗ រហូតដល់សព្វថ្ងៃ ។

លោកគ្រូអង្គនេះ គង់នៅយូរបន្តិចទៅ មានកិត្តិសព្ទទូទៅគ្រប់ស្រុកភូមិ ។ ព្រះនាងបានឮដំណឹងថា លោកគ្រូនោះទើបតែនិមន្តមកពីស្រុកក្រៅ ចេះមន្តវិជ្ជាការល្បីល្បាញដូច្នោះ មានព្រះបំណងចង់ជួប នឹងលោក ដើម្បីចង់ដឹងអំពីសេចក្តីទុក្ខរបស់ព្រះនាងថា "តើថ្ងៃណានឹងស្រាកស្រាន្តស្បើយល្ហើយ " ព្រះនាងក៏ប្រាប់ពួកអ្នកបម្រើឲ្យរៀបព្រះទីន័ងដំរី ដើម្បីទៅថ្វាយបង្គំលោកគ្រូ កែវ ។ លុះធ្វើព្រះដំណើរ ទៅដល់ទីកន្លែងលោកគ្រូនោះហើយ ព្រះនាងចូលទៅថ្វាយបង្គំលោកតាមទំនៀម ទ្រង់បានឃើញលក្ខ ណៈលោកគ្រូអង្គនោះសព្វគ្រប់ ក៏បែកចិត្តចេញពីសង្សារចាស់ មកជាប់នឹងលោកគ្រូកែវនោះវិញ ពី ព្រោះលោកអង្គនោះ មានរូបស្អាតជាងបណ្ឌិតស្រី ពេញលក្ខណៈជាប្រុសគួរឲ្យស្រឡាញ់ ព្រះនាង ដំណាលពីសេចក្តីទុក្ខរបស់ព្រះនាងទូលលោកគ្រូសព្វគ្រប់ហើយ ក៏សំដែងអាការស្និទ្ធស្នាលហាក់ដូច ជាទុកចិត្តគ្នាយូរមកហើយ ។ អាការដែលព្រះនាងពណ៌នារឿងរ៉ាវរបស់ព្រះនាងនោះនាំឲ្យលោកគ្រូ កែវ ស្គាល់បានថា ព្រះនាងជាប់ជំពាក់នឹងលោក ។ លោកគ្រូ កែវ អត់ទ្រាំពុំបានក៏មានចិត្តទោរទន់ទៅ រកព្រះនាង ហើយមានពុទ្ធដីកាទន់ភ្លន់ទៅរក ។ កាលបើព្រះនាងបានឮពុទ្ធដីកាលោកផ្អែមល្ហែមទន់ ភ្លន់មករកដូច្នេះ ក៏សង្ឃឹមថា "តទៅមុខអញនឹងមានអាង លែងកើតទុកតាំងពីថ្ងៃនេះតទៅហើយ... ។ ចាប់តាំងពីថ្ងៃនោះមក ព្រះនាងមានពណ៌សម្បុរស្រស់បំព្រងដូចស្រីទេពអប្សរ ។ ចំណែកឯលោកគ្រូ កែវវិញ លោកខំប្រឹងពិចារណាធម៌ដើម្បីដកចិត្តពីព្រះនាងនោះខ្លាំងណាស់ដែរ តែលោកដកពុំរួចសោះ ។ ពេលក្រោយមក ព្រះនាងត្រឡប់ទៅថ្វាយបង្គំសុំឲ្យលោកគ្រូស្រោចទឹក ដើម្បីឲ្យមានសិរីសួស្តី ។ ពេលទៅស្រោចទឹកនោះ ព្រះនាងក៏រឹតតែសំដែងអាការរាក់ទាក់ទៅរកលោកគ្រូ កែវ ខ្លាំងឡើងថែម ទៀត ហើយព្រះនាងទូលថា "សូមឲ្យលោកម្ចាស់គង់នៅសប្បាយចុះ" ។ កាលបើឮពាក្យនោះ លោក គ្រូកែវ ក៏ក្រៀមក្រំស្រពោនមុខកើតទុក្ខដោយសំដីព្រះនាង ។ អាការរបស់លោក ជាអាការប្រាប់ព្រះ នាងឲ្យជ្រាបច្បាស់ថា "លោកកើតទុក្ខពីព្រោះព្រះនាង" ។ ព្រះនាងក៏រឹតតែមានសេចក្តីស្រឡាញ់ខ្លាំង ឡើងទៀត ដល់ព្រះនាងត្រឡប់ទៅព្រះដំណាក់វិញ កើតទុក្ខផ្ទំពុំលក់ សោយក្រយាស្ងោយពុំបាន អត់ ទ្រាំពុំបាន ក៏បម្រើឲ្យរៀបចំព្រះទីន័ងដំរី ទៅនិមន្តលោកមកឯព្រះដំណាក់ព្រះនាង ។ ឯលោកគ្រូ កែវ កាលបើបានឃើញអ្នកបម្រើទៅនិមន្ត ក៏សប្បាយព្រះទ័យណាស់ បានរៀបចំដំណើរនិមន្តមកជា ប្រញាប់ ។ ព្រះនាងក៏ទំនុកបម្រុងបណីតភោជន សុទ្ធតែរបស់ប្លែកៗ ។ លុះលោកនិមន្តទៅដល់ ព្រះ នាងលើកមកប្រគេនលោកផ្ទាល់ព្រះអង្គ ។ លោកគ្រូ កែវ ឆាន់ពុំបាន ។ អាការដែលលោកឆាន់មិន បាននោះ ជាអាការប្រាប់ព្រះនាងឲ្យជ្រាបរឹតតែច្បាស់ ព្រះនាងក៏កើតទុក្ខខ្លាំងឡើងៗ អត់ទ្រាំកេរ្តិ៍ខ្មាស ពុំបានក៏ចូលទៅទូលលោកថា " សូមលោកម្ចាស់សឹកចាកសិក្ខាបទមកចុះ " ហើយព្រះនាងប្រគេន សំពត់ស្លៀកពាក់ព្រមទាំងប្រដាប់ប្រដាសព្វគ្រប់ ។

លោកទទួលព្រមតាមសំដីព្រះនាងនិមន្ត ហើយក៏សឹកចាកសិក្ខាបទជាយរាវាសនៅរួមសុខជាមួយព្រះនាងខ្មៅ នៅក្នុងប្រាសាទនោះ ។

ដោយមានរឿងដំណាលដូច្នេះ បានជាប្រាសាទនោះ គេហៅថា " ប្រាសាទនាងខ្មៅ " តាំងពីនោះរហូតមក ។

ចំណេរកាលមកខាងក្រោយ មានពុទ្ធបរិស័ទជ្រះថ្លា ស្ថាបនាវត្តនៅទីនោះឡើង វត្តក៏មានឈ្មោះថា " វត្តប្រាសាទនាងខ្មៅ " រហូតមកដល់សព្វថ្ងៃ ។